東京外大 東南アジア学 Southeast Asian Studies TUFS No. 26, 139-150, 2020

# ការសិក្សាអត្ថបទរឿងរាមកេរ្តិ៍នៅមធ្យមសិក្សាទុតិយភូមិ

# Analyzing Ramakerti in Cambodian Khmer-Language Textbooks

កែប សុគន្ធារតន៍

Kep Sokunthearath

**東京外国語大学世界言語社会教育センター**

World Language and Society Education Centre,

Tokyo University of Foreign Studies

## 要旨

本稿は、カンボジアで現在、中等教育課程で使用されている国語教科書に掲載されている、文学作品『リアムケー』をとりあげ、同作品を通して、学習者に何を学ばせようとしているのかを分析するものである。『リアムケー』は、ラーマーヤナのカンボジア版であり、アンコール遺跡の彫刻、王宮寺院の壁画、パフォーミングアーツなどに題材として取り上げられており、カンボジア人が最も誇る文学作品である。具体的には、教科書に掲載されている設問、そして教師用参考書に書かれている正解を分析する。その結果、学習者は『リアムケー』を通して、古典文学の分析方法、また伝統的な行事の意義、カンボジア人としてのアイデンティティを学ぶことが期待されていることが明らかになった。

This paper discusses Ramakerti, a literary work that is currently used in the Cambodian secondary education curriculum, and analyzes what students are meant to learn through this work. Ramakerti is the Cambodian version of Ramayana, depicted in sculptures of the ruins of Angkor, wall paintings of the royal temples, the performing arts, and so forth. It is one of the literary works the Cambodians are most proud of. Specifically, I analyzed the questions in the textbooks, the correct answers in the reference books for teachers, and the self-study video teaching materials distributed by the Cambodian Ministry of Education. As a result, it became clear that through Ramakerti, the students are expected to learn about the significance of traditional events, their identity as Cambodians, and how to analyze classical literature.

キーワード：カンボジア，国語，教科書

者が保持し、クリエイティブ・コモンズ表示 4.0 国際ライセンス(CC-BY)下に提供します。
ons.org/licenses/by/4.0/deed.ja

Keywords: Cambodia, National Language, Textbook

# សេចក្តីផ្តើម

គោលបំណងនៃអត្ថបទនេះ គឺសិក្សាវិភាគតាមរយៈសំណួរនៃអត្ថបទដកស្រង់ពីរឿងរាមកេរ្តិ៍ដែលមាននៅក្នុងសៀវភៅ ភាសាខ្មែរ ថ្នាក់ទី ១០ (២០១៥), សៀវភៅ អក្សរសាស្ត្រខ្មែរ ថ្នាក់ទី ១១ (២០១៥) និង ថ្នាក់ទី ១២ (២០១៦) ដែលជាឯកសារគោលរបស់ក្រសួងអប់រំសម្រាប់រៀននិងបង្រៀនភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរនៅមធ្យមសិក្សាទុតិយភូមិ និង ចម្លើយពីក្នុងសៀវភៅកិច្ចតែងការបង្រៀន និពន្ធដោយលោកគ្រូ អ្នក សាលី, ២០១៧, ព្រមទាំង វីដេអូ វេទិកា សំណួរនិងចម្លើយ នៃការបង្រៀន ភាសាខ្មែរ ថ្នាក់ទី១២ «សិក្សាអត្ថបទរឿងរាមកេរ្តិ៍» ដោយសាស្ត្រាចារ្យ កង សុខុម, វិទ្យាល័យបាក់ទូក, ចាក់ផ្សាយនៅលើបណ្តាញសង្គមហ្វេសប៊ុក Krou Cambodia នាខែ មិថុនា ២០២០ សម្រាប់សិស្សានុសិស្សសិក្សាក្នុងដំណាក់កាលដែលសាលាទូទាំងប្រទេសត្រូវបិទទ្វារដោយសារការរីករាលដាលនៃមេរោគកូវីដ១៩។

ប្រជាជនខ្មែរទូទៅធ្លាប់បានឮឈ្មោះនិងដឹងដំណើររឿងខ្លះៗអំពីរឿងរាមកេរ្តិ៍។ គេស្គាល់រឿងនេះតាមរយៈគំនូរ[1] , តាមរយៈសាស្ត្រាក្បួនហោរ[2] សម្រាប់ចាក់គម្ពីរផ្សងមើលជោគជតា, តាមរយៈការទស្សនារបាំបុរាណនិងល្ខោន, តាមរយៈការស្តាប់ការនិទានរបស់មនុស្សចាស់ៗដែលចេះចាំរឿង និង ការពោល ឬ ស្មូត របស់សិល្បករល្បីៗ មាន តាគ្រុឌ តាចក់ និង តាសយ ។ល។ រីឯអត្ថបទសំណេរ ឬ អត្ថបទអក្សរសិល្ប៍រឿង រាមកេរ្តិ៍ ដែលយើងអាចរកអានបានសព្វថ្ងៃនេះ មាន រាមកេរ្តិ៍នៃតាចក់, រាមកេរ្តិ៍ ពោលដោយ តាសយ និង រឿងរាមកេរ្តិ៍ ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ១៩៩៥។

ចំពោះការសិក្សាស្រាវជ្រាវនិងវិភាគអត្ថបទអក្សរសិល្ប៍ «រឿងរាមកេរ្តិ៍» នេះ យើងឃើញមាននៅក្នុងសៀវភៅ «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» និពន្ធដោយ លោកបណ្ឌិតសភាចារ្យឃីង ហុកឌី, ១៩៩៧, «វិជ្ជានិពន្ធន៍ខ្មែរចម្រុះ» និពន្ធដោយ សែម-សូរ, ព.ស.២៥០៦,គ.ស.១៩៦៣, «រឿងរាមកេរ្តិ៍» សម្រាប់ថ្នាក់ទី ១០, ដោយ វ៉ា សារឿន, ១៩៩៣, «សិក្សាអត្ថបទអក្សរសិល្ប៍» ថ្នាក់ទី១២, លាង ហាប់អាន, «ការសិក្សារឿងរាមកេរ្តិ៍ », ម. ត្រាណេ, ១៩៩៥។ល។

លោកបណ្ឌិតសភាចារ្យ យឹង ហុកឌី បានលើកឡើងថា អត្ថបទអក្សរសិល្ប៍រឿងរាមកេរ្តិ៍ត្រូវបានដាក់ក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា និង ឧត្តមសិក្សា នៅឆ្នាំ ១៩៥៨-១៩៧៥។ បច្ចុប្បន្ននេះ អត្ថបទអក្សរសិល្ប៍រឿងរាមកេរ្តិ៍ ក៏ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាទាំងនៅមធ្យមសិក្សានិងឧត្តមសិក្សាដែរ។

## I. អត្ថបទរឿងរាមកេរ្តិ៍ក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាទុតិយភូមិ

អត្ថបទដកស្រង់រឿងរាមកេរ្តិ៍ឃើញមាននៅក្នុងសៀវភៅភាសាខ្មែរថ្នាក់ទី១០, សៀវភៅអក្សរសាស្ត្រខ្មែរ ថ្នាក់ទី ១១ និង ថ្នាក់ទី ១២ ដែលជាឯកសារគោលរបស់ក្រសួងអប់រំសម្រាប់រៀននិងបង្រៀនភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរនៅមធ្យមសិក្សាទុតិយភូមិ។ នៅក្នុងអារម្ភកថានៃឯកសារគោលខាងលើនេះ គេលើកឡើងថា មានបង្ហាញប្រធានបទសំខាន់ៗស្តីពីវប្បធម៌ ទំនៀមទំលាប់ ប្រពៃណី និង ការសិក្សាអក្សរសាស្ត្រ-អក្សរសិល្ប៍ជាគោលនៃការសិក្សាបំណិនច្រើនបែបដូចជា ការសង្ខេប សំយោគ តែងសេចក្តី វិភាគអត្ថបទជាដើម ដែលមានកម្រិតខ្ពស់និងស៊ីជម្រៅនិងជួយបង្កើនចំណេះដឹងអក្សរសិល្ប៍ដល់សិស្សឱ្យកាន់តែទូលំទូលាយ តាមរយៈអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ អក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប អត្ថបទអត្ថាធិប្បាយ ពាក្យរាយ ពាក្យកាព្យ ល្ខោន ចម្រៀង របាំ វេយ្យាករណ៍ និងសិល្ប៍វិធីតែង និពន្ធដ៏សំបូរបែបរបស់អ្នកនិពន្ធកវីជាតិល្បីៗ។ តាមរយៈខ្លឹមសារ បំណិន សំណួរលំហាត់ ការសិក្សាគន្លឹះ នៅក្នុងសៀវភៅទាំងនេះ ជំរុញឱ្យអ្នកសិក្សាមានការអភិវឌ្ឍនិងទទួលបានបំណិន ចំណេះដឹងកាន់តែស៊ីជម្រៅថែមទៀតលើផ្នែកភាសាខ្មែរ មានលក្ខណៈឯកទេសដើម្បីផ្សារភ្ជាប់ទៅនឹងការសិក្សានៅឧត្តមសិក្សាផងនិងត្រៀមអាជីពផង។

អត្ថបទដកស្រង់ពី «រឿងរាមកេរ្តិ៍» ឃើញមាននៅក្នុងមេរៀនទី៣ អំពី «ការគោរពបូជា» នៃសៀវភៅ ភាសាខ្មែរ ថ្នាក់ទី១០, មេរៀនទី៦ អំពី «ការគោរពបូជា» នៃសៀវភៅ អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ និង មេរៀនទី២ អំពី «អក្សរសិល្ប៍ព្រាហ្មណ៍និយម» នៃសៀវភៅ អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២។ ចំពោះមេរៀន «ការគោរពបូជា»នេះ គេរំពឹងថា សិស្សនឹងបានរៀនពីការគោរពបូជាមួយចំនួនតាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរ និងគោលគំនិតសំខាន់ៗមួយចំនួនរបស់ព្រះពុទ្ធសាសនា និង ព្រាហ្មណ៍សាសនា ដែលមានឥទ្ធិពលទៅលើប្រទេសកម្ពុជា និងបានជ្រៀតចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាស្ទើរគ្រប់ស្រទាប់វណ្ណៈតាំងពីយូរណាស់មកហើយ ។ ជំនឿទាំងនេះបានក្លាយទៅជាប្រពៃណី ទំនៀមទម្លាប់ និងការគោរពបូជា ការប្រតិបត្តិរបស់ប្រជាជនខ្មែរទូទៅមាន ការគោរពមាតាបិតា គ្រូអាចារ្យ គោរពព្រះពុទ្ធ ព្រះឥន្ទ្រ ព្រះព្រហ្មជា

ដើម។ល។

ដោយឡែក លោកគ្រូ អ្នក សាលី (ទំព័រទី ២២១) បានលើកឡើងថា ការសិក្សា អត្ថបទដកស្រង់ពីរឿងរាមកេរ្តិ៍ក្នុងមុខវិជ្ជាអក្សរសាស្ត្រខ្មែរថ្នាក់ទី១១ គឺដើម្បីឱ្យសិស្សស្គាល់ពីប្រភពអត្ថបទ ប្រភេទអត្ថបទ តួអង្គ លក្ខណៈមនុស្ស តម្លៃអប់រំក្នុងអត្ថបទ, ចេះកំណត់មូលន័យនិងគំនិតសំខាន់ៗក្នុងអត្ថបទបានច្បាស់លាស់ ហើយសិស្សនឹងគោរពប្រតិបត្តិនូវលិទ្ធដែលសមស្របតាមជំនឿខ្មែរ និង អនុវត្តតាមការអប់រំនៃលទ្ធិទាំងនោះ។

សំណួរទាក់ទងនឹងអត្ថបទដកស្រង់ពីរឿងរាមកេរ្តិ៍ដែលគេប្រើជាវិធីមួយក្នុងការធ្វើឱ្យសម្រេចគោលបំណងនិងក្តីរំពឹងដែលបានលើកឡើងខាងលើនេះ មានចំនួន២៧ (ថ្នាក់ទី១០: ពី១-៥, ថ្នាក់ទី១១: ពី ៦-១២, ថ្នាក់ទី១២: ពី ១៣-១៨, ថ្នាក់អនឡាញ: ពី ១៩-២៣, ប្រធានតែងសេចក្តីទាំងបីថ្នាក់: ពី ២៤-២៧) ៖

(១) តើអត្ថបទកាព្យនេះមានចំណងជើងដូចម្តេច? ដកស្រង់ពីរឿងណា? ក្នុងខ្សែទីប៉ុន្មាន? បោះពុម្ពផ្សាយក្នុងឆ្នាំណា?

(២) ចូរបង្ហាញកាលកំណត់តែងនិងសង្គមបរិយាកាស?

(៣) ក្នុងអត្ថបទដកស្រង់នេះ អ្នកនិពន្ធប្រើវិធីអ្វីខ្លះ?

(៤) តើអត្ថបទដកស្រង់រឿងរាមកេរ្តិ៍ស្ថិតនៅក្នុងអក្សរសិល្ប៍ប្រភេទណា? ចូរពន្យល់លក្ខណៈសម្គាល់របស់រឿងនេះ។

(៥) ចូរបង្ហាញគំនិតសំខាន់ៗក្នុងអត្ថបទ។

(៦) តើអត្ថបទខាងលើនេះមានប្រភពដកស្រង់ចេញពីរឿងណា? បទអ្វីខ្លះ?

(៧) ចូរប្រាប់តួអង្គក្នុងអត្ថបទនេះ?

(៨) តើអត្ថបទនេះតែងក្នុងសម័យកាលណា?

(៩) ចូរប្រាប់មូលន័យនៅក្នុងអត្ថបទ។

(១០) ចូរកំណត់គំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ។

(១១) ចូរបង្ហាញលក្ខណៈមនុស្សតាមរយៈអត្ថបទនេះ។

(១២) ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងអត្ថបទនេះ។

(១៣) ចូបង្ហាញពីប្រភពនិង ប្រភេទរបស់អត្ថបទដកស្រង់។

(១៤) ចូរបង្ហាញពីលក្ខណៈព្រាហ្មណ៍និយមនៅក្នុងអត្ថបទដកស្រង់នេះ។

(១៥) តើអត្ថបទនេះមានតួអង្គណាខ្លះ?

(១៦) ចូរបង្ហាញកាលអាកាសរបស់អត្ថបទនេះ។

(១៧) ចូរបង្ហាញពីវិធីតែងនិពន្ធ (ពណ៌នាវិធី សំវាទវិធី ឧបមានវិធី បដិវិធី វចនវិធី...) ដែលអ្នកនិពន្ធប្រើ។

(១៨) ចូរសង្ខេបអត្ថបទនេះ ជាពាក្យរាយ។

(១៩) តើរឿងរាមកេរ្តិ៍ស្ថិតក្នុងចលនាអក្សរសិល្ប៍អ្វី?

(២០) រឿងរាមកេរ្តិ៍មានប្រភពមកពីណា?

(២១) ហេតុអ្វីព្រះរាមធ្វើឱ្យព្រៃដែលកំពុងរោលរាលដោយកម្តៅព្រះអគ្គីប្រែប្រួលបាន?

(២២) ព្រះរាមសម្រេចព្រះទ័យតាំងអាស្រមនៅឯណា?

(២៣) បើតាមទំនៀមទម្លាប់ខ្មែរពិធីមង្គលការត្រូវប្រារព្ធឡើងនៅកន្លែងណា?

(២៤) ប្រៀបធៀបលក្ខណសម្បត្តិនៃតួអង្គព្រះរាមក្នុងរឿងបែបព្រាហ្មណ៍និយមនិងតួអង្គព្រះវេស្សន្តរក្នុងរឿងបែបពុទ្ធនិយម។

(២៥) ចូរអ្នកធ្វើការប្រៀបធៀបលក្ខណៈសម្បត្តិរបស់តួអង្គព្រះនាងសីតាក្នុងរឿងបែបព្រាហ្មណ៍និយមនិងតួអង្គនាងមទ្រីក្នុងរឿងបែបពុទ្ធនិយម។

(២៦) តើរាមកេរ្តិ៍និងរឿងរាមាយណៈ មានទំនាក់ទំនងនិងឥទ្ធិពលទៅលើគ្នាដូចម្តេចខ្លះ?

(២៧) តើតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខុសពីព្រះរាមក្នុងរឿងរាមាយណៈដូចម្តេចខ្លះ?

## II. ការវិភាគសំណួរនៃអត្ថបទដកស្រង់រឿងរាមកេរ្តិ៍ក្នុងសៀវភៅសិក្សាគោល

សំណួរទាំងឡាយខាងលើនេះអាចចែកជា ៤ ប្រភេទ គឺ ១ ប្រភេទសំណួរដែលទាក់ទងនឹងការបង្ហាញអត្ថបទ ២ ប្រភេទសំណួរដែលទាក់ទងនឹងការវិភាគអត្ថបទ ៣ ប្រភេទសំណួរដែលទាក់ទងនឹងអត្ថន័យនៃអត្ថបទ និង ៤ ប្រភេទសំណួរដែលទាក់ទងនឹងអត្ថរូបនៃអត្ថបទ។

### 1. សំណួរដែលទាក់ទងនឹងការបង្ហាញអត្ថបទ

ក្នុងការសិក្សាឱ្យបានច្បាស់អំពីការបង្ហាញអត្ថបទ គេប្រើសំណួរចំនួន៨ក្នុងចំណោមសំណួរទាំង២៧ខាងលើនេះគឺ សំណួរ (១), (២), (៤), (៦), (៨), (១៣), (១៩) និង(២០)។ សិស្សនឹងបានដឹងច្បាស់អំពីចំណងជើងនិងប្រភពអត្ថបទ ប្រភេទរឿង ឬ ប្រភេទអក្សរសិល្ប៍តាមរយៈអំណានអត្ថបទដែលមាននៅក្នុងសៀវភៅមេរៀន។ ចំណែកឯព័ត៌មានអំពីប្រភពរឿង កាលកំណត់តែង និងសង្គមបរិយាកាស ពុំមាននៅក្នុងអត្ថបទមេរៀនទេ ដូច្នេះសិស្សត្រូវស្តាប់គ្រូបង្រៀននិយាយប្រាប់។ ដូចជាការបង្រៀនរបស់សាស្ត្រាចារ្យ កង សុខុម គាត់ប្រាប់សិស្សថា គេពុំដឹងថារឿងរាមកេរ្តិ៍នេះតែងឡើងពេលណា ដោយអ្នកនិពន្ធណាមួយច្បាស់លាស់ទេ។ គេគ្រាន់តែដឹងថា រឿងនេះរៀបរៀងឡើងដោយព្រះអង្គម្ចាស់វ័ឌ្ឍឆាយាវង្ស។ ចំណែកឯការកំណត់តែង ប្រហែលជានៅរវាងស.វ. ១១-១២ នៅពេលដែល

ខ្មែរកំពុងប្រកាន់ខ្ជាប់លទ្ធិសាសនាព្រាហ្មណ៍ ហើយថារឿងនេះមានប្រភពមកពីរឿង រាមាយណៈរបស់វាល្មិកិជនជាតិឥណ្ឌា ជារឿងដ៏ល្បី ត្រូវប្រទេសជាច្រើនយកទៅធ្វើនិយកម្ម ដើម្បីឱ្យក្លាយទៅជាអក្សរសាស្ត្ររបស់ជាតិ ខណៈដែលប្រទេសទាំងឡាយនោះកាន់សាសនា ព្រាហ្មណ៍ដូចគ្នា។

2. សំណួរដែលទាក់ទងនឹងការវិភាគអត្ថបទ

ក្នុងការសិក្សាអំពីការវិភាគអត្ថបទ គេប្រើសំណួរចំនួន ៦ គឺ (៧), (១៤), (១៥), (១៦) (១៨) និង (២២) ។ តាមរយៈសំណួរទាំង៦នេះ សិស្សទទួលបានបំណិនក្នុងការប្រាប់តួអង្គ បង្ហាញលក្ខណៈព្រាហ្មណ៍និយម និងកាលអាកាសក្នុងអត្ថបទ ព្រមទាំងសង្ខេបអត្ថបទកាព្យ ជាពាក្យរាយបានត្រឹមត្រូវល្អ បន្ទាប់ពីគេបានអានអត្ថបទនិងស្តាប់សេចក្តីពន្យល់របស់គ្រូ បង្រៀន។ លក្ខណៈព្រាហ្មណ៍និយម មានការបង្ហាញពីភាពអច្ឆរិយរបស់ព្រះរាមជាតួអង្គ អវតារទី៧របស់ព្រះវិស្ណុមានមហិទ្ធិឫទ្ធិអស្ចារ្យ យាងទៅដល់ទីណា ធម្មជាតិព្រៃព្រឹក្សានៅទី នោះដែលធ្លាប់តែក្រៀមក្រោះប្រែជារីកស្រស់មានផ្លែផ្កា។ ម្យ៉ាងទៀតពរស្តុតី ឬ សេចក្តី សរសើរ, សេចក្តីស៊ើចដែលព្រះពិស្វាមិត្រសូត្រថ្វាយជ័យមង្គលចំពោះព្រះរាម ពេលព្រះរាម រំលឹកពរនោះធ្វើឱ្យកម្តៅព្រះអាទិត្យត្រជាក់ដូចជាពន្លឺច័ន្ទ ព្រៃដែលកំពុងដុតរោលរាលដោយ កម្តៅព្រះអគ្គីប្រែប្រួលទៅជាលូតលាស់ចោលម្លប់ទ្រឈឹងទ្រ មានផ្ការីកស្គុះស្គាយ, ព្រានព្រៃ ដែលធ្លាប់តែបរបាញ់សត្វទៅជាសំឡាញ់សត្វ, សត្វតិរច្ឆានទៅជាស្លូត កូនខ្លាទៅបៅដោះមេ ប្រើស កូនប្រើសទៅបៅមេខ្លា។ ព្រះរាមអវតារទី៧ព្រះវិស្ណុមានឫទ្ធិអំណាចអស្ចារ្យឈ្នះគេក្នុង ការប្រឡងធ្នូរ ហើយបានអភិសេកនឹងនាងសីតា។

3. សំណួរដែលទាក់ទងនឹងអត្ថន័យ

ក្នុងការសិក្សាអំពីអត្ថន័យនៃអត្ថបទ គេប្រើសំណួរចំនួន ១0 គឺ សំណួរ(៥), (៩), (១០), (១១), (១២), (២១), (២២), (២៣), (២៤), (២៥) និង (២៨)។ ការសិក្សាអំពីអត្ថន័យនេះ មានការ ផ្តោតចិត្តទុកដាក់ខ្លាំងជាងគេ។ តាមរយៈអំណានអត្ថបទ សិស្សអាចឆ្លើយសំណួរ ពីគំនិត សំខាន់ៗ មូលន័យ លក្ខណៈមនុស្ស និង តម្លៃអប់រំក្នុងអត្ថបទ; ពីលក្ខណៈសម្បត្តិព្រះរាម និងព្រះនាងសីតាដែលជាតួអង្គក្នុងរឿងបែបព្រាហ្មណ៍និយម។ សិស្សក៏ដឹងពីមហិទ្ធិឫទ្ធិស្តុតី ដែលព្រះពិស្វាមិត្រឱ្យព្រះរាម, យល់ពីមូលហេតុដែលព្រះរាមមិនព្រមស្នាក់នៅជិតអាស្រម ឥសីភារទ្វាជ ហើយក៏ទៅតាំងអាស្រមនៅជើងភ្នំចិត្រកូដតាមការណែនាំរបស់ឥសីភារទ្វាជ។

សិស្សក៏អាចយល់ពីទំនាក់ទំនងរវាងទំនៀមទំលាប់ខ្មែរក្នុងសង្គមខ្មែរបច្ចុប្បន្ននិង ទំនៀម ទំលាប់ក្នុងរឿងរាមកេរ្តិ៍។ ចំណុចនេះសាស្ត្រាចារ្យ កង សុខុមបានលើកឡើងថា មានទិដ្ឋភាព

អរិយធម៌ខ្មែរខ្លះៗនៅក្នុងរឿងរាមកេរ្តិ៍។ ទិដ្ឋភាពទាំងនោះរួមមាន ព្រះរាជពិធីច្រត់ព្រះន័ង្គល, ការជ្រើសរើសគូស្រករឱ្យកូនស្រី, មង្គលការនៅផ្ទះឬនគរខាងស្រី, និយមពាក្យសច្ចៈ, ជឿលើមហិទ្ធិឫទ្ធិអាទិទេព, កុកជាសត្វចង្រៃ និង ការដំកល់សព។ គាត់ពន្យល់ថា «រឿងរាមកេរ្តិ៍យើងធ្វើនិយកម្មចេញពីរឿងរាមាយណៈរបស់ឥណ្ឌា ក៏ប៉ុន្តែហេតុអ្វីបានជាទិដ្ឋភាពអរិយធម៌ខ្មែរមាននៅក្នុងដំណើររឿងនេះ? កាលណាយើងធ្វើនិយកម្មរឿងមួយ យើងអត់រក្សាសភាពដើមទេ យើងអត់ទុកសភាពដើមនៅលក្ខណៈបរទេសទេ ព្រោះខ្មែរប្រសប់ក្នុងការធ្វើនិយកម្ម ក្នុងការយកមកកិន ក្នុងការយកមកទំពារ ធ្វើយ៉ាងណាឲ្យទៅជាលក្ខណៈជាតិ។ អញ្ចឹងហើយបានជាយើងឃើញថារាល់ទិដ្ឋភាព អរិយធម៌ខ្មែរច្រើនត្រូវកវីនិពន្ធស្នាដៃរឿងនេះ បានបញ្ជ្រាបបានបញ្ចូល ទិដ្ឋភាពអរិយធម៌ទាំងនោះ ដែលជារបស់ខ្មែរនៅក្នុងដំណើររឿង ទើបរឿងនេះគេហៅថារឿងដែលមានទិដ្ឋភាពអរិយធម៌ខ្មែរច្រើន។»

ជាការត្រឹមត្រូវណាស់ដែលថា កវីនិពន្ធខ្មែរបានយករឿងរាមាយណៈរបស់ឥណ្ឌាមកធ្វើនិយកម្ម មកកិន មកទំពារ ធ្វើវាឲ្យទៅជារឿងមួយមានលក្ខណៈជាតិ។ នេះមានន័យថា កវីនិពន្ធខ្មែរអាចរក្សានិងបញ្ចូលចំណុចខ្លះដែលស្របនឹងអរិយធម៌ខ្មែរក្នុងគ្រាលោកតែងរឿងនោះឡើង ហើយក៏អាចបញ្ចេញចោលនូវចំណុចដែលមិនសមស្របនឹងអរិយធម៌ខ្មែរដែរ។

តាមការអះអាងខាងលើនេះ មានន័យថា «ព្រះរាជពិធីច្រត់ព្រះន័ង្គល, ការជ្រើសរើសគូស្រករឱ្យកូនស្រី, មង្គលការនៅផ្ទះឬនគរខាងស្រី, និយមពាក្យសច្ចៈ, ជឿលើមហិទ្ធិឫទ្ធិអាទិទេព, កុកជាសត្វចង្រៃ និង ការដំកល់សព» គ្មានទេនៅក្នុងរឿងរាមាយណៈរបស់ឥណ្ឌា គឺមានតែក្នុងរឿងរាមកេរ្តិ៍ខ្មែរប៉ុណ្ណោះ ដោយសារកវីនិពន្ធខ្មែរបាន«បញ្ជ្រាប បានបញ្ចូល ទិដ្ឋភាពអរិយធម៌ទាំងនោះ ដែលជារបស់ខ្មែរនៅក្នុងដំណើររឿង»។

ការលើកឡើងបែបនេះ គឺជាការយល់ច្រឡំមួយ។ កវីនិពន្ធខ្មែរលោកបានរក្សាចំណុចទាំងនេះក្នុងរឿងរាមកេរ្តិ៍ខ្មែរ ក៏ព្រោះបានលោកឃើញខ្មែរយើងប្រតិបត្តិនូវទំនៀមទំលាប់បែបនេះដែរ ក្នុងសង្គមដែលលោកកំពុងរស់នៅ។ ម្យ៉ាងទៀត រឿងរាមាយណៈរបស់ឥណ្ឌានេះនិពន្ធដោយកវីវាល្មិកិដែលជាព្រាហ្មណ៍។ ដូច្នេះ ស្នាដៃរបស់លោក អាចចាត់ទុកជាគម្ពីរ ឬ ក្បួនច្បាប់សម្រាប់ក្សត្រក៏ដូចជាមនុស្សក្នុងសាសនាព្រាហ្មណ៍ប្រកាន់យក។ សូមរំលឹកផងដែរថា អំពីមេរៀន «ការគោរពបូជា» មានការរំពឹងថា សិស្សនឹងបានរៀនពីការគោរពបូជាមួយចំនួនតាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរ និងគោលគំនិតសំខាន់ៗមួយចំនួនរបស់ព្រះពុទ្ធសាសនា និងព្រាហ្មណ៍សាសនា ដែលមានឥទ្ធិពលទៅលើប្រទេសកម្ពុជា និងបានជ្រៀតចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាស្ទើរគ្រប់ស្រទាប់វណ្ណៈតាំងពីយូរណាស់មកហើយៗ ជំនឿទាំងនេះបានក្លាយទៅជាប្រពៃណី ទំនៀមទម្លាប់ និងការគោរពបូជា ការប្រតិបត្តិរបស់ប្រជាជនខ្មែរទូទៅ»។

យោងទៅតាមសេចក្ដីរំពឹងនេះ គេអាចបកស្រាយបញ្ជាសវិញ គឺទិដ្ឋភាពអរិយធម៌ក្នុងរឿងរាមាយណៈរបស់ឥណ្ឌា មានឥទ្ធិពលទៅលើអរិយធម៌ខ្មែរនិងបានជ្រៀតចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជា រហូតទៅជាមានលក្ខណៈជាតិជ្រៀលជ្រៅ។

ពិធីច្រត់ព្រះនង្គ័លដែលព្រះបាទជនកធ្វើនៅនគរមិថិលានោះ នៅខ្មែរយើងវាជាពិធីដែលធ្វើតាមទំនៀមទំលាប់ប្រពៃណីរបស់ជាតិប្រចាំឆ្នាំ។ ព្រះរាជពិធីនេះធ្វើឡើងក្នុងអត្ថន័យៈ ១ ការបើករដូវកាលកសិកម្ម បានន័យថារដូវកាលកសិកម្មមកដល់ហើយ។ ២ ជំនឿការបួងសួង បន់ស្រន់ ដល់ម្ចាស់ទឹកម្ចាស់ដី ឲ្យបង្អុរទឹកភ្លៀងគ្រប់គ្រាន់ សម្រាប់កសិកម្ម ព្រោះធ្វើស្រែពឹងលើទឹកភ្លៀង និង ផ្សងមើលថានៅឆ្នាំខាងមុខដំណាំអ្វីផ្ដល់ភោគផលល្អ និងដំណាំអ្វីមិនបានផល។

ពិធីលើកធ្នូដើម្បីជ្រើសរើសគូរស្រករឲ្យនាងសីតាដែលព្រះបាទជនកលោកបានរៀបចំឡើងនោះ ក៏មាននៅក្នុងផ្នត់គំនិតខ្មែរដែរ។ ព្រះបាទជនកលោកចង់ជ្រើសរើសបុរសមានសម្ថភាព។ សាស្ត្រាចារ្យ កង សុខុមពន្យល់ថា « ឪពុកម្ដាយខ្មែរមានទម្លាប់ទុកដាក់កូនចៅ ឲ្យមានគូស្រករ ជាពិសិសេសកូនស្រី លោកពិនិត្យសម្លឹងមើលទៅលើសម្ថភាពកូនប្រុស។ ហេតុអីបានជាគាត់ត្រូវតែសម្លឹងមើលសមត្ថភាពកូនប្រុស ព្រោះថាកូនប្រុសនេះ គេចាត់ទុកដូចជាជើងមុខ។ កូនស្រីគេចាត់ទុកដូជាជើងក្រោយ។ អញ្ចឹងជើងក្រោយតាមជើងមុខ កាលណាជើងមុខមិនមាំទេ ជើងមុខអត់ខ្លាំងទេ ជើងមុខអត់សមត្ថភាពទេ អត់មានក្ដីសុខទេគ្រួសារហ្នឹង។ ជើងក្រោយដួលតាម។ កូនប្រុសប្រៀបដូចជាមេគ្រួសារ កូនស្រីត្រឹមតែជាមេផ្ទះទេ។ នេះដើម្បីឲ្យកូនស្រីមានអនាគតល្អ។ ព្រោះគាត់គិតថា គូជីវិតរបស់កូនត្រូវតែមួយជីវិត។

ការគោរពពាក្យសច្ចៈ ពាក្យពិត ឬ ពាក្យសត្យ- នៅក្នុងរឿងរាមកេរ្តិ៍ ព្រះបាទជនកលើកព្រះនាងសីតាឲ្យជាមហេសីព្រះរាមពេលព្រះរាមលើកធ្នូរួច ព្រោះសន្យាហើយ, ព្រះរាមយាងទៅព្រៃ១៤ឆ្នាំ ព្រោះព្រះបាទទសរថសន្យានឹងនាងកៃកេសី, ព្រះបាទទសរថឈឺចាប់រហូតដល់បាតបង់ព្រះជន្ម ព្រោះតែលោកមិនបោះបង់ពាក្យសន្យាជាមួយនាងកៃកេសីទេ។ ចំណុចនេះ កង សុខុម ពន្យល់ពីទម្លាប់របស់ខ្មែរថា «ខ្មែរនិយមយកសំដីជាឯក លេខជាទោ អក្សរជាត្រី។ សំដីបើនិយាយទៅហើយ គេចាត់ទុកថាបានការ ។ គេប្រៀបដូចជារនាប រនាបបាក់ គេអាចយករនាបជួស បើសំដីហួស គ្មានអីជួសបានទេ។ ម្យ៉ាងទៀតយើងតែងឮមនុស្សខ្មែរយើងនិយាយថា ទឹកមាត់ បើស្ដោះហើយ មិនអាចលេបវិញបានទេ។ អញ្ចឹងសំដីបើនិយាយហើយចាត់ទុកថាបានការ មនុស្សដែលគោរពពាក្យសំដី គេចាត់ទុកជាមនុស្សមានតម្លៃ ។ អញ្ចឹងបើនិយាយ ហ៊ានទទួលខុសត្រូវលើសំដីខ្លួន។ »

ព្រះបាទជនករៀបមង្គលការនៅនគររបស់ព្រះអង្គ។ កង សុខុម ពន្យល់ពីទម្លាប់ខ្មែរថា «ជាទម្លាប់របស់ខ្មែរ ពិធីមង្គលការត្រូវ តែធ្វើឡើងនៅផ្ទះខាងស្រី។ ម៉េចបានត្រូវធ្វើនៅផ្ទះខាង

ស្រី? នេះជាការឲ្យតម្លៃកូនស្រី ការលើកកិត្តិយស ការបង្ហាញពីបវេណីរបស់ជាតិ យកស្ត្រីជាធំ។ »

ការជឿលើមហិទ្ធិឫទ្ធអាទិទេព- នៅក្នុងរឿងរាមកេរ្តិ៍ព្រះរាមជាអវតារព្រះវិស្ណុមានមហិទ្ធិឫទ្ធិអស្ចារ្យ ចុះមកបង្ក្រាបពួករាពណ៍ដែលចូលចិត្តរាត្បាតលោក។ កង សុខុម ពន្យល់ពីទម្លាប់ខ្មែរថា «ខ្មែរតែងតែចាត់ទុកបុគ្គលដែលមានភាពខ្លាំងពូកែ បុគ្គលដែលអស្ចារ្យ ថាជាតំណាងអាទិទេពចុះមកសង្គ្រោះលោក ឬចុះមកបង្ក្រាបសភាវៈអាក្រក់ណាមួយ»។

ការនិយមថាកុកជាសត្វចង្រៃ- នៅក្នុងដំណើររឿងរាមកេរ្តិ៍ នៅពេលដែលសត្វកុកនាំដំណឹងនាងសីតាទៅប្រាប់ព្រះរាមៗអត់បានអរគុណកុកទេ តែព្រះរាមព្រះលក្ស្មណ៍ បែរជាជេរប្រមាថកុក។ កង សុខុម ពន្យល់ពីទម្លាប់ខ្មែរថា «ជាទម្លាប់ ជាបវេណី ជាផ្នត់គំនិតរបស់ខ្មែរកាលណានិយាយពីសត្វកុក គេគិតថាសត្វកុកគឺជាសត្វចង្រៃ។ សត្វដែលនាំមកនូវភាពឧបទ្រុប។ អ្នកដែលអត់ដឹងពីផ្នត់គំនិតខ្មែរ គេគិតថាព្រះរាមព្រះលក្ស្មណ៍រមើលគុណណាស់។ តែបើអ្នកដឹងពីផ្នតគំនិតខ្មែរ ទើបដឹងថា សំដីសត្វចង្រៃគឺជាសំដីអពមង្គល យកជាការអត់បាន។»

ការបកស្រាយលើចំណុចចុងក្រោយនេះ អាចចាត់ទុកជាការបកស្រាយតាមផ្នត់គំនិតរបស់ខ្លួន។ ដោយសារតែខ្មែរមានជំនឿថា សត្វព្រៃមួយចំនួនឱ្យប្រផ្នូលចង្រៃ។ តែបើគេទុកផ្នត់គំនិតនោះមួយឡែកសិន កុំឱ្យវាមានឥទ្ធិពលលើការគិតរបស់គេ ហើយបែរទៅពិចារណាតាមស្ថានភាពនៃរឿងនោះវិញនោះ គេអាចគិតថា ព្រះរាមព្រះលក្ស្មណ៍ ទើបតែបាញ់កលសត្វប្រើសមាស ដូច្នេះលោកទាំងពីរប្រាកដជាគិតថា កុកនេះក៏ជាយក្សក្រឡាខ្លួនមកបញ្ឆោតដែរ។

នៅក្នុងវេទិកាសំណួរចម្លើយនេះ សិស្សបានសួរសំណួរដែលទាក់ទងអត្ថន័យដែរ។ គេសួរ៖

១ មូលហេតុព្រះរាមយាងចូលព្រៃ?

២ ពាក្យសត្យព្រះរាមគឺជាអ្វី?

៣ ហេតុអ្វីហនុមានជាបុត្រព្រះអាទិត្យ?

៤ ហេតុអ្វីសីតានិងព្រះរាមមិនបានរស់នៅជាមួយគ្នា?

៥ តើព្រះរាមធ្វើសង្គ្រាមជាមួយក្រុងរាពណ៍ប៉ះពាល់ផលប្រយោជន៍អ្វី?

៦ រឿងរាមកេរ្តិ៍មានលក្ខណៈមនុស្សដែរឬទេ?

៧ ហេតុអ្វីព្រះរាមលួចបាញ់ពាលី?

ក្នុងចំណោមសំណួរទាំង៧ខាងលើនេះ មាន ៤ សំណួរ ( ៣, ៤, ៥, ៧) មិនទាក់ទងនឹងអត្ថបទនៅក្នុងសៀវភៅមេរៀន ក៏ប៉ុន្តែវាទាក់ទងនឹងខ្សែក្រោយៗ។ នេះសឱ្យឃើញថា សិស្ស

ស្គាល់រឿងរាមកេរ្តិ៍ច្រើនជាងអត្ថបទដែលគេអាន ហើយគេចាប់អារម្មណ៍ទៅលើអត្ថន័យនៃរឿង។

4. សំណួរដែលទាក់ទងនឹងអត្ថរូប

ក្នុងការសិក្សាអំពីអត្ថរូបគេប្រើសំណួរចំនួនតែ ៤ ប៉ុណ្ណោះគឺ (៣), (៦) និង (១៧) (2៧) ដែលទាក់ទងនឹង វិធីតែងនិពន្ធដែលអ្នកនិន្ធប្រើនិងបទកាព្យ ។ ឧទាហរណ៍

-ពណ៌នាវិធី -រៀបរាប់ទិដ្ឋភាពនៃព្រៃក្នុងរដូវក្តៅ ឧ.ស្លឹកខ្លះខ្លោខ្លះបីក្រហម....

-សំវាទវិធី- រវាងឥសីពាទ្វាទ្យនិងព្រះរាម ឧ.ហៃក្សត្រទ្រង់ឫទ្ធិចេស្តា ស្តេចមកពីណា ...

-ឧបមានវិធី- ឧ.ននោងគឺសីតាទេពី ចម្ប៉ាពិសី គឺអង្គព្រះលក្ស្មណ៍អនុជា... រីកន្លង់នោះគឺធ្យូងផង ជាមន្ទិល ហ្មងដូចពាក្យនាងកៃកេសី...។

## III. សន្និដ្ឋាន

យោងតាមការសិក្សាសំណួរនិងចម្លើយនៃអត្ថបទដកស្រង់ពីអត្ថបទរឿងរាមកេរ្តិ៍ក្នុងឯកសារគោលទាំងនោះ និងតាមការបង្រៀនយើងអាចសន្និដ្ឋានបានថា ការសិក្សាអត្ថបទរឿងរាមកេរ្តិ៍នៅមធ្យមសិក្សាទុតិយភូមិនេះ គេផ្តោតសំខាន់ទៅលើទាំងការបង្ហាញអត្ថបទ ការវិភាគអត្ថបទ អត្ថន័យនិងអត្ថរស។ សំណួរទាំងអស់នោះ ត្រូវបានរៀបចំជាដំណាក់ៗ។ រាល់ការសិក្សាអត្ថបទដកស្រង់ពីរឿងរាមកេរ្តិ៍ (ភាសាខ្មែរថ្នាក់ទី១០, អក្សរសាស្រ្តខ្មែរថ្នាក់ទី១១ និង ១២) តែងតែមានសំណួរ អំពី ចំណងជើង ប្រភពអត្ថបទ ប្រភពរឿង ប្រភេទអក្សរសិល្ប៍សម្រាប់ស្ទាបស្ទង់ចំណេះដឹងរបស់សិស្ស។ ថ្វីត្បិតតែព័ត៌មាននេះ មានខ្លះ ពុំមាននៅក្នុងអត្ថបទអំណាន ប៉ុន្តែប្រហែលអ្នករៀបចំឯកសារសិក្សានេះ គេយល់ថាវាសំខាន់ដែលចាំបាច់ត្រូវតែដឹងហើយ បានជាគេសួរសំណួរទាក់ទងនឹងការបង្ហាញអត្ថបទនេះតាំងពីថ្នាក់ទី១០រហូតដល់ថ្នាក់ទី១២។ បន្ទាប់មកមានសំណួរស្ទាបស្ទង់បំណិនអំណានរបស់សិស្ស។ ព័ត៌មានទាំងអស់សម្រាប់វិភាគអត្ថបទ មានព័ត៌មាននៅក្នុងអត្ថបទអំណានហើយ សិស្សគ្រាន់តែអាននិងវិភាគព័ត៌មានទាំងនោះ ថាមួយណាជាតួអង្គ ជាលក្ខណៈព្រាហ្មណ៍និយម ជាកាលអាកាស ជាអត្ថរូប (កំណាព្យ, បទ, វីធី..) និងធ្វើការសង្ខេបអត្ថបទ។ ជំហានបន្ទាប់ដែលជាដំណាក់កាលសំខាន់និងទូលំទូលាយគឺអត្ថន័យ ដោយផ្តោតទៅគំនិតសំខាន់ៗ តម្លៃអប់រំលក្ខណៈសម្បត្តិព្រះរាមនិងព្រះនាងសីតាដែលជាតួអង្គប្រុសស្រីក្នុងរឿងបែបព្រាហ្មណ៍និយម និង ទិដ្ឋភាពអរិយធម៌នៅក្នុងរឿងរាមកេរ្តិ៍ដែល មានឥទ្ធិពលទៅលើប្រទេសកម្ពុជា និងបានជ្រៀតចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាស្ទើរគ្រប់ស្រទាប់រហូតមកដល់ពេល

នេះ ហើយជំនឿទាំងនេះបានក្លាយទៅជាប្រពៃណី ទំនៀមទម្លាប់ និងការគោរពបូជា ការប្រតិបត្តិរបស់ប្រជាជនខ្មែរទូទៅ។ ទិដ្ឋភាពទាំងឡាយនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងអរិយធម៌ខ្មែរតាំងពីយូរលង់មកហើយៗ វាបានស្ថិតក្នុងផ្នត់គំនិតខ្មែរ វាជាអត្តសញ្ញាណជាតិខ្មែរ ដែលកូនខ្មែរគ្រប់រូបមានភារកិច្ចថែរក្សា។ ចំពោះបញ្ហាថា ទិដ្ឋភាពអរិយធម៌ក្នុងរឿងរាមកេរ្តិ៍បែបព្រាហ្មណ៍និយមនេះ មានឥទ្ធិពលលើអរិយធម៌ខ្មែរ ឬ កវីនិពន្ធខ្មែរបញ្ជ្រាប បញ្ចូលអរិយធម៌ខ្មែរទៅក្នុងរឿងកេរ្តិ៍នោះ ត្រូវមានការស្រាវជ្រាវរកអំណះអំណាងបន្ថែមទៀត។

ការសិក្សាបន្តខ្ញុំចង់សិក្សារឿងបែបពុទ្ធនិយមនៅក្នុងកម្មវិធីសិក្សានៅទុតិយភូមិដូចជារឿងទុំទាវជាដើម។

注

[1] ឧទាហរណ៍គំនូរនិទានពីរឿងរាមកេរ្តិ៍នៅថែវវិហារព្រះកែវមរកតនៅក្នុងបរិវេណព្រះបរមរាជវាំង

[2] គេដកដំណើររឿងខ្លះៗ ពីរឿងរាមកេរ្តិ៍សម្រាប់អធិប្បាយពន្យល់

## ឯកសារពិគ្រោះ

កង សុខុម. វីដេអូ ភាសាខ្មែរ ថ្នាក់ទី ១២, សិកស្សាអត្ថបទរឿងរាមកេរ្តិ៍

ក្រសួងអប់រំ យុវជន និង កីឡា. ២០១៥. ភាសាខ្មែរ ថ្នាក់ទី១០, គ្រឹះស្ថានដោះពុម្ពនិងចែកផ្សាយ, គ្រឹះស្ថានដោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និង កីឡា. ២០១៥. អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១, គ្រឹះស្ថានដោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និង កីឡា. ២០១៦. អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២, គ្រឹះស្ថានដោះពុម្ពនិងចែកផ្សាយ

ឃីង ហុកឌី. ១៩៩៧. ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ

នាយកដ្ឋានអភិវឌ្ឍកម្មវិធិសិក្សាសិក្សា. ២០១៩. អត្ថបទអក្សរសិល្ប៍ សម្រាប់មធ្យមសិក្សាទុតិយភូមិ

ម. ត្រាណេ. ១៩៩៥. ការសិក្សា រឿងរាមកេរ្តិ៍, ដំរីស

វ៉ា សារឿន. ១៩៩៣. រឿងរាមកេរ្តិ៍

សរ សារុន. សង្ខេបរឿងរាមកេរ្តិ៍, (ពុំមាន ព័ត៌មានពីការបោះពុម្ព និង ឆ្នាំនៃការបោះពុម្ពទេ)

សែម សូរ. ១៩៦៣. វិជ្ជានិពន្ធន៍ខ្មែរចម្រុះ សម្រាប់ថ្នាក់ទី ៤ និងទី ៣ ទំនើបនៃ វិទ្យាល័យ-អនុវិទ្យាល័យ និងការប្រឡងមធ្យមសិក្សាប័ត្រ, បណ្ណាគារភ្នំពេញ, ១០៩-១២០
អ្នក សាលី. ២០១៧. កិច្ចតែងការបង្រៀន